# GOD'S SIMPLE PLAN OF SALVATION

## Introduction

១ យ៉ូហាន 5:13 [១៣] ខ្ញុំសរសេរសេចក្ដីនេះមកអ្នករាល់គ្នា ដើម្បីអោយអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាដែលជឿលើព្រះនាមព្រះបុត្រារបស់ព្រះជាម្ចាស់ មានជីវិតអស់កល្បជានិច្ចហើយ។

## I យើងទាំងអស់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប

រ៉ូម 3:10 [១០] ដូចមានចែងទុកមកថា៖ *«គ្មានមនុស្សណាសុចរិតឡើយ សូម្បីតែម្នាក់ក៏គ្មានផង*

រ៉ូម 3:23 [២៣] **គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ.**



**យើងទាំងអស់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប**

## II ការស្លាប់ដោយគ្មានទីបញ្ចប់គឺជាអ្វីដែលយើងបានទទួលតាមរយៈការប្រព្រឹត្តិបាប ។

រ៉ូម 6:23 [២៣] **ដ្បិតលទ្ធផលនៃបាប គឺសេចក្ដីស្លាប់ រីឯព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ គឺជីវិតអស់កល្បជានិច្ច រួមជាមួយព្រះគ្រិស្ដយេស៊ូ ជាព្រះអម្ចាស់នៃយើង។**

រ៉ូម 5:12 [១២] តាមរយៈមនុស្សតែម្នាក់ បាប*បានចូលមកក្នុងពិភពលោក ហើយតាម
រយៈបាប សេចក្ដីស្លាប់ក៏ចូលមកដែរ។ ហេតុនេះហើយបានជាសេចក្ដីស្លាប់រាលដាល
ដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្ដអំពើបាប។

វិវរណៈ 21:8 [៨] ពួកកំសាក ពួកមិនជឿ ពួកប្រព្រឹត្ដអំពើគួរស្អប់ខ្ពើម ពួកសម្លាប់គេ
ពួកប្រាសចាកសីលធម៌ ពួកគ្រូធ្មប់ ពួកថ្វាយបង្គំព្រះក្លែងក្លាយ និងពួកកុហក
ទាំងប៉ុន្មាន នឹងទទួលទោសនៅក្នុងបឹងភ្លើង និងស្ពាន់ធ័រដែលកំពុងតែឆេះ»។
នេះហើយជាសេចក្ដីស្លាប់ទីពីរ។

## III ព្រះគ្រិស្ត ទ្រង់ ពានសុគតនៅលើឈើឆ្កាង ដើម្បីទទួលរងនូវទណ្ឌកម្មជំនួសយើងទាំងអស់គ្នា គឺសេចក្តី ស្លាប់ ។

រ៉ូម 5:8 [៨] រីឯព្រះជាម្ចាស់វិញ ព្រះអង្គបានបង្ហាញព្រះហឫទ័យស្រឡាញ់របស់
ព្រះអង្គចំពោះយើង គឺព្រះគ្រិស្ដបានសោយទិវង្គតសំរាប់យើង ក្នុងពេល
ដែលយើងនៅជាមនុស្សជាប់បាបនៅឡើយ។

រ៉ូម 14:9 [៩] ដ្បិតព្រះគ្រិស្ដបានសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
ដើម្បីធ្វើជាព្រះអម្ចាស់ទាំងលើមនុស្សស្លាប់ទាំងលើមនុស្សរស់។

រ៉ូម 6:23 [២៣] **ដ្បិតលទ្ធផលនៃបាប គឺសេចក្ដីស្លាប់ រីឯព្រះអំណោយទានរបស់
ព្រះជាម្ចាស់វិញ គឺជីវិតអស់កល្បជានិច្ច រួមជាមួយព្រះគ្រិស្ដយេស៊ូ ជាព្រះអម្ចាស់នៃ
យើង។**



**Christ died for sinners!**

## IV គឺអ្នកបានត្រឹមតែទទួលការលើកលែងទោសពីព្រះដោយជំនឿ

កិច្ចការ 4:12 [១២] ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបាន
ទាល់តែសោះ ដ្បិតនៅក្រោមមេឃនេះ ព្រះជាម្ចាស់ពុំបានប្រទាននាមណា
មួយផ្សេងទៀតមកមនុស្ស ដើម្បីសង្គ្រោះយើងនោះឡើយ»។

អេភេសូ 2:8-9 [៨] ព្រះអង្គសង្គ្រោះបងប្អូនដោយសារព្រះគុណ តាមរយៈជំនឿ។
ការសង្គ្រោះមិនមែនមកពីបងប្អូនទេ គឺជាព្រះអំណោយទានរបស់
ព្រះជាម្ចាស់ [៩] ហើយក៏មិនមែនមកពីមនុស្សប្រព្រឹត្តអំពើល្អដែរ ដើម្បីកុំ
អោយនរណាម្នាក់អួតខ្លួនបាន។

ទីតុស 3:5 [៥] អោយមានចិត្តធ្ងន់ មានចរិយាបរិសុទ្ធ យកចិត្តទុកដាក់នឹងកិច្ចការ
ក្នុងផ្ទះសំបែង មានចិត្តល្អ គោរពចុះចូលនឹងស្វាមីរៀងៗខ្លួន។ ធ្វើដូច្នេះ គ្មាន
នរណាអាចមួលបង្កាច់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានឡើយ។




## V បាបដែលអ្នកបានប្រព្រឹត្តនឹងនៅមានឪកាសផ្ញើទៅបាន ប្រសិនបើអ្នកមានជំនឿលើព្រះគ្រិស្ត ។

រ៉ូម 10:9-10 ៩ ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្ត
អ្នកជឿថា ព្រះជាម្ចាស់ពិតជាបានប្រោសព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញ
មែន នោះអ្នកនឹងទទួលការសង្គ្រោះជាមិនខាន ១០ ដ្បិតបើចិត្តយើងជឿ យើងនឹង
បានសុចរិត ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ

រ៉ូម 1013 ១៣ ដ្បិត *«អ្នកណាអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ»*។

*តាមរយៈការអនុគ្រោះនិងភាពមានមេត្តារបស់ទ្រង់ ។ ប្រសិនបើអ្នកចង់ទទួលព្រះយេស៊ូវគ្រិស្ត ថាជាអ្នកជួយសង្គ្រោះអ្នក ដើម្បីទទួលការលើកលែងទោសពីព្រះ អ្នកត្រូវសូត្របទលើកតំកើងព្រះដូចខាងក្រោម ។ សូមចងចាំថា ការសូត្រពាក្យសសើរនេះ ឬពាក្យសសើរ ផ្សេងទៀត អ្នកនឹងមិនបានទទួលការស្រោចស្រង់ពីព្រះជាម្ចាស់ទេ ប្រសិនបើអ្នកគ្មានជំនឿ លើទ្រង់នោះ ។ មានតែការជឿលើព្រះគ្រិស្តទេទើបអ្នកអាចរួមផុតពីអំពើបាបបា*

*ន ។ ពាក្យសូត្រសសើរនេះ គឺជាការបញ្ជាក់អំពីជំនឿរបស់អ្នកចំពោះព្រះអង្គ ហើយថ្លែងអំណរគុណ ចំពោះទ្រង់ដែលបានជួយស្រោចស្រង់អ្នក ។*



**“ព្រះជាម្ចាស់**

**ទូលបង្គំដឹងថាទូលបង្គំមាន កំហុសចំពោះព្រះអង្គ ហើយទូលបង្គំសមតែទទួលទោស ។ ទូលបង្គំបានងាកចេញពីអំពើបាបទាំងនោះ មានជំនឿស៊ុបចំពោះការសង្គ្រោះរបស់ព្រះអង្គ ។ ទូលបង្គំសូមអរព្រះគុណចំពោះការសង្គ្រោះនិងការអភ័យទោសរបស់ព្រះអង្គ ដែលជាអំណោយសំរាប់ជីវិត ជាអមតះ! សាធុ!” ។**



**Amazing Grace Publishing *PO Box 1963 * Joshua TX 76058 * 817-426-1828 * E-Mail JamesAV@aol.com**